# ២១_រឿង អាប៉ាងនាងតី

ក្នុងសម័យមួយនោះ ជារដូវស្រូវទុំ អាប៉ាងទៅដេកចាំស្រូវវាទាំងយប់ថ្ងៃ មានទាំងចាប៉ីមួយទៅផង វេលាថ្ងៃឡើងមើលថែទាំស្រូវដល់ពេលយប់ទំនេរតែងដេញចាប៉ីហើយស្រែកច្រៀងផង ។ លុះច្រៀងរាល់យប់ទៅ មានខ្មោចស្រីម្នាក់ ឮសូរចម្រៀងច្រៀងចាប៉ីពីរោះពេក ក៏ដើរទៅស្តាប់ទៅអង្គុយអាំងភ្លើងក្រោមខ្ទមអាប៉ាង យូរបន្តិចទៅអាប៉ាងក្រឡេកទៅក្រោមផ្ទះឃើញខ្មោចដែលដំណែងខ្លួននោះ អង្គុយអាំងភ្លើង អាប៉ាងសួរថា "អាណាអង្គុយក្រោមខ្ទមនេះ ?" ។ មេខ្មោចប្រាប់ថា "ខ្ញុំ" ។ អាប៉ាងថា "ប្រហែលជាខ្មោចទេ" ។ មេខ្មោចឆ្លើយថា "ខ្មោចថាមិនខ្មោច" ។ អាប៉ាងសួរទៀតថា "ហាងឯងឈ្មោះអីមករកអី" ។ មេខ្មោចឆ្លើយថា "ខ្ញុំឈ្មោះតីខ្ញុំមកស្តាប់ចាប៉ី" ។ អាប៉ាងថា "ឡើងមកបើមកស្តាប់ចាប៉ី" ។ មេខ្មោចឡើងទៅអង្គុយជិតអាប៉ាងៗ ក៏ស្រឡាញ់យកគ្នាជាប្តីប្រពន្ធទៅ ។ លុះដល់រួចស្រូវ មេខ្មោចនោះក៏សួរទៅអាប៉ាងថា "ឥឡូវរួចស្រូវហើយ តើឯងព្រមយកអញឬទេ ? បើឯងមិនយកអញៗ នឹងកាច់យកឯង" ។ អាប៉ាងថា "អញព្រមយកប៉ុន្តែចាំអញដឹកស្រូវទៅទុកផ្ទះសិន" ។ លុះអាប៉ាងដឹកស្រូវយកទៅទុករួចហើយ ក៏ត្រឡប់មកយកមេកន្តីនោះវិញ ។ មេកន្តីក៏នាំអាប៉ាងទៅសំពះជម្រាបសួរ ពួកបងប្អូនខ្មោចទាំងប៉ុន្មាន រួចក៏នៅជាមួយគ្នាទៅ ។

ប្រហែលជាង ១ខែពួកខ្មោចទាំងប៉ុន្មានបបួលគ្នាព្រមទាំងអាប៉ាងអោយទៅរកសត្វមកធ្វើជាអាហារ ។អាប៉ាងក៏ទៅជាមួយនឹងពួកខ្មោចនោះ លុះទៅដល់ពាក់កណ្តាលព្រៃដើមត្រថុក ដែលខ្មោចទាំងបួនសំគាល់ថា ដើមឈើទាលបានប្រទះនឹងកង្កែបមួយ ខ្មោចទាំងនោះស្រែកថា "ប្រយ័ត្នរុីកនយើង! ដំរីធំណាស់ទៅហើយ" ។ អាប៉ាងឮគេស្រែកថាដំរី ក៏ប្រឹងរកមើលមិនឃើញដំរីសោះឃើញតែកង្កែបលោតមកត្រង់មុខអាប៉ាង អាប៉ាងក៏ចាប់ដាក់ក្នុងថ្នក់សំពត់ទៅ ។ ខ្មោចអស់នោះចេះតែស្រែកថា "ប្រយ័ត្នរុីដំរីស្តមួយធំណាស់" ហើយស្រែកសួរអាប៉ាងថា "អាប៉ាងឃើញដំរីទេ ? " អាប៉ាងស្រែកថា

"មិនឃើញទេ" ។ ពួកខ្មោចក៏នាំគ្នាដើរមកដល់ជិតអាប៉ាងហើយថា "ទៅអាប៉ាងទៅផ្ទះយើងរកសត្វមិនបានទេ" ។ អាប៉ាងថា "អញបានកង្កែបមួយ" ។ ខ្មោចទាំងនោះសួរទៅអាប៉ាងថា "យ៉ាងដូចម្តេចអាប៉ាងកង្កែបនោះ ឯងចែកអោយយើងរាល់គ្នាស៊ីផង" ។ អាប៉ាងដកកង្កែបពីថ្នក់ហើយបង្ហាញទៅពួកខ្មោចនោះ ។ ខ្មោចអស់នោះឃើញ ក៏នាំគ្នារត់ព្រោងព្រាតអស់ទៅហើយមានវាចាថា "ទុកប្តីមេកន្តីអោយនៅមិនបានទេ ព្រោះវាខ្លាំងពូកែណាស់វាហ៊ានចាប់ដីរីយកទៅដាក់ក្នុងថ្នក់វា បើដូច្នេះយើងអោយអាប៉ាងនេះនៅមិនបានទេអោយវាទៅវិញចុះ" ។ អាប៉ាងក៏បានរួចខ្លួនហើយត្រឡប់មកផ្ទះវិញ ។

## ល្ងង់មើលតែខ្មោច